00420922

C26/9/1

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
17 / 12 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 23 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៣៦)
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក ខៀវ សំផន
ដាក់ជូន: អង្គបុរេជំនុំជម្រះ
ភាសាដើម: បារាំង
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ **សាធារណៈ / Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច**
**លើការពន្យារថេរវេលាឃុំខ្លួនបណ្ដោះអាសន្ន**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក ខៀវ សំផន**
លោក ស ស្វាន
លោក Jacques VERGÈS

**ជំនួយការ**
លោកស្រី សេង សុជាតា
កញ្ញា Charlotte MOREAU
លោក Uldis KRASTINS
កញ្ញា Coralie COLSON

<u>ផ្ញើរជូន</u>៖

**ចៅក្រមអង្គបុរេជំនុំជម្រះ**
លោក ប្រាក់ គឹមសាន
លោក ន័យ ថុល
លោក ហួត វុទ្ធី
លោកស្រី Katinka LAHUIS
លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង**
**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានតំណាង**

# សូមគោរពអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

១. តាមរយៈសេចក្តីជូនដំណឹងចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ និងស្របតាមវិធាន៦៣ (៧) សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ "ជនត្រូវចោទ និងមេធាវីទាំងឡាយគាត់ ថា ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានកំណត់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៨ វិច្ឆិកា ២០០៨ (នឹង)ត្រូវផុតកំណត់នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយថា សហចៅក្រមស៊ើបអង្កេតមានបំណងនឹងបន្តថេរវេលានៃការឃុំខ្លួននេះតទៅទៀត ។"[1]

២. ជាការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងនេះ ហើយស្របទៅនឹងថេរវេលាដែលបានកំណត់ សហមេធាវីការពារបានធ្វើ "សេចក្តីជំទាស់ទៅនឹង ការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន" កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩[2]។ សហមេធាវីការពារបានដាក់បញ្ចូលទៅក្នុងបណ្តឹងឧទ្ធរណ៍នេះ នូវយោបល់ទាំងឡាយដែលខ្លួនបានលើកឡើងនៅក្នុងសេចក្តីជំទាស់នោះ។

៣. កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យមានការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន សម្រាប់រយៈពេលអតិបរមាមួយឆ្នាំ[3]។ នៅក្នុងដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងអំពីហេតុផលណាមួយ ដែលតម្រូវឱ្យមានការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្ននោះទេ ហើយក៏មិនបានឆ្លើយតបទៅនឹងយោបល់ទាំងឡាយ ដែលសហមេធាវីការពារក្តីបានលើកឡើងនៅក្នុងសេចក្តីជំទាស់របស់ខ្លួនដែរ។

---

[1] សេចក្តីជូនដំណឹង វិធាន ៦៣.៧ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩ *ឯកសារតុលាការលេខ C26/6*

[2] សេចក្តីជំទាស់ទៅនឹងការបន្តរយៈពេលឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ *ឯកសារតុលាការលេខ C26/7* ("សេចក្តីជំទាស់")

[3] ដីកាសម្រេចស្តីពីការបន្តរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩, *ឯកសារតុលាការលេខ C26/8* ("ដីកា")

៤. សហមេធាវីការពារសូមស្នើដល់អង្គបុរេជំនុំជម្រះ មេត្តាសម្រេចឱ្យមានការដោះលែងលោក ខៀវ សំផន ជាបន្ទាន់។

## II. សម្អាងច្បាប់

៥. ដូចដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ថា *"ការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ គឺជាករណីអញ្ញត្រកម្មទៅនឹងគោលការណ៍ទូទៅដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពក្នុងដំណាក់កាលស៊ើបសួរ។ ហេតុនេះ ជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន តែក្នុងករណីដែលថា លក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ។"*[4] អង្គបុរេជំនុំជម្រះក៏បានឯកភាពការវិភាគបែបនេះដែរ [5]។

៦. ម្យ៉ាងទៀត វិធាន ៦៣.៣ បានចែងផងដែរថា:

*សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម:*

*ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសម្រេចសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។*

*ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានការណ៍ចាំបាច់ ដើម្បី:*

> *១. រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។*

---

[4] ដីកា កថាខណ្ឌទី១៣

[5] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ *ឯកសារតុលាការលេខ C26/5/26 កថាខណ្ឌទី ៩០* ("សាលដីកា")

*២. ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។*

*៣. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។*

*៤. ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ*

*៥. រក្សាសណ្តាប់ធ្នាប់សាធារណៈ*

## III. អំណះអំណាងនៃបណ្តឹងឧទ្ធរណ៍

### ១. ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត?

៧. ជាបឋម ចាំបាច់យើងត្រូវកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយវិធាន ៦៣.៧ ដោយភ័ន្តច្រលំ។ វិធាន ៦៣.៧ ចែងអំពីបន្ទុកនៃភស្តុតាងដែលត្រូវធ្លាក់ទៅលើសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចជាលាយលក្ខណ៍អក្សរ និងមានហេតុផលគ្រប់គ្រាន់ ដើម្បីធ្វើជាសម្អាងក្នុងការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្ននោះ។ ប៉ុន្តែនៅក្នុងដីកាសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានធ្វើការ *"សន្និដ្ឋានថា គ្មានការផ្លាស់ប្តូរណាមួយ បានកើតឡើងចំពោះករណីនេះទេ"*[6] ហើយសហចៅក្រមស៊ើបអង្កេតហាក់ដូចជាពេញចិត្ត ក្នុងការលើកឡើងពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។

៨. ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌមុនៗ ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការពិសេស និងមានគោលដៅដកហូតសេរីភាពពីធម្មជាតិពីជនណាម្នាក់។ វិធានការនេះមិនអាចត្រូវបានអនុវត្ត ដោយគ្មានការវិភាគល្អិតល្អន់ និងស៊ីជម្រៅលើកាលៈទេសៈជាក់ស្តែងឡើយ។ ដោយគ្រាន់តែធ្វើការសន្និដ្ឋានថា ស្ថានភាពត្រូវបានគេជឿថា គ្មានការប្រែប្រួលខុសពីមុន ហើយក៏បង្គាប់ឱ្យមានការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្ន ដោយគ្មានមូលហេតុត្រឹមត្រូវ ទង្វើនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើគោលការណ៍សន្មតជាមុនថា គ្មានទោស។

៩. អង្គបុរេជំនុំជម្រះ បានលើកឡើងថា ផ្អែកលើវិធាន ៦៤.១ និង ៦៤.២ នៃវិធានផ្ទៃក្នុង ជនត្រូវចោទត្រូវតែទទួលបានការដោះលែង *"ប្រសិនណាបើលក្ខខណ្ឌតម្រូវនៃការឃុំខ្លួនបណ្តោះ*

---

[6] ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី២៤ និង ២៧

*អាសន្នដូចមានចែងក្នុងវិធាន៦៣ លែងត្រូវបំពេញទៀតហើយ*[7]។ ប្រសិនណាការអះអាងនេះអាចមានលក្ខណៈសមស្រប នៅពេលដែលមានការស្នើសុំដោះលែងជនត្រូវចោទពីសំណាក់មេធាវីការពារក្តី ហើយបានដាក់បន្ទុកនៃភស្តុតាងពីការប្រែប្រួលនៃកាលៈទេសៈទៅលើសហមេធាវីការពារនោះ ការអះអាងនេះមិនអាចត្រូវបានអនុវត្តនៅក្នុងដំណាក់កាលនៃការចេញដីកាសម្រេចសម្រេចពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្នបានទេ។ សហចៅក្រមស៊ើបអង្កេតជាអ្នកដែលមានភារកិច្ចក្នុងការបង្ហាញថា វាមានហេតុផលពិតប្រាកដដែលអាចឱ្យជឿបានថាជននោះពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬច្រើន ដូចដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយថា ការឃុំខ្លួនត្រូវតែចាំបាច់ ដោយឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដូចមានចែងក្នុងវិធាន ៦៣.៣.ខ) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេតត្រូវចេញសេចក្តីសម្រេចមួយដែល មានអំណះអំណាងគ្រប់គ្រាន់ ហើយដែលមានបង្ហាញភស្តុតាងពីកាលៈទេសៈនានាដូចបានលើកឡើងនោះ។ ករណីនេះពាក់ព័ន្ធទៅនឹងការអនុវត្តគោលការណ៍សន្មតថាគ្មានទោស ដែលគោលការណ៍នេះនឹងត្រូវបានរំលោភបំពានយ៉ាងខ្លាំង ប្រសិនណាបើគេតម្រូវឱ្យមេធាវីការពារស្វែងរកភស្តុតាងដើម្បីបញ្ជាក់អំពីសេរីភាពដែលកូនក្តីខ្លួនត្រូវទទួលបាននោះ។

## ២. អំពីការអនុវត្តវិធាន ៦៣.៣.ក) នៃវិធានផ្ទៃក្នុង

១០. ធាតុផ្សំដំបូងនៃវិធានដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន គឺការបង្ហាញពីមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គបុរេជំនុំជម្រះប្រកាន់យកគោលការណ៍ដែលថា "*មានអង្គហេតុ ឬព័ត៌មាននានាដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍ឯករាជ្យម្នាក់ជឿជាក់បានថា ជនត្រូវចោទអាចនឹងទទួលខុសត្រូវចំពោះបទល្មើស ដែលត្រូវបានចោទប្រកាន់*"[8]។

---

[7] សាលដីកា ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២00៨ កថាខណ្ឌទី២១

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ នួន ជា ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២00៨ *ឯកសារតុលាការលេខ C9/4/6* កថាខណ្ឌទី២៤

១១. នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាសម្រេចបដិសេធលើសំណើសុំដោះលែង និងការពន្យារថេរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានលើកឡើងថា *"ពុំមានភស្តុតាង ដោះបន្ទុកណាមួយត្រូវបានដាក់នៅក្នុងសំណុំរឿង បន្ទាប់ពីមានការចេញដីកាសម្រេចសម្រេចបន្តថេរវេលានៃការឃុំខ្លួននោះឡើយ ហើយដែលនេះនាំឲ្យគេសន្និដ្ឋានថា លក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធាន ៦៣.៣.ក) នៃវិធានផ្ទៃក្នុងនៅតែត្រូវបានបំពេញ។"*[9] សហចៅក្រមស៊ើបអង្កេតខ្លួនឯងក៏បានគូសបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនថា៖ *ភស្តុតាងមួយចំនួនដែលប្រមូលបានក្នុងអំឡុងពេលនេះ អាចជាភស្តុតាងដោះបន្ទុកទាក់ទងនឹងកម្រិតអំណាចរបស់ ខៀវ សំផន នៅក្នុងជួរ ប.ក.ក ទំហំការងារ និងការធ្វើដំណើររបស់គាត់នៅក្នុងប្រទេសកម្ពុជា ឬការយល់ដឹងរបស់គាត់អំពីមន្ទីរសន្តិសុខ ឬ មន្ទីរពេទ្យ"*[10]

១២. នៅពេលអានអំណះអំណាងទាំងពីរនេះ វាហាក់ដូចជាលំបាកនឹងជឿថា អ្នកសង្កេតការណ៍ឯករាជ្យម្នាក់អាចធ្វើការសន្និដ្ឋានបានថា មានមូលហេតុគួរឲ្យជឿជាក់ច្បាស់ថាជនត្រូវចោទនោះអាចធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយសហមេធាវីការពារសូមអះអាងថា លក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធាន ៦៣.៣.ក) នៃវិធានផ្ទៃក្នុង មិនត្រូវបានបំពេញឡើយ ក្នុងករណីនេះ។

១៣. ក្នុងគ្រប់ករណីទាំងអស់ និងផ្អែកលើយុត្តិសាស្ត្រនៃតុលាការអន្តរជាតិ ប្រសិនណាការបន្តទទួលស្គាល់នូវមូលហេតុនានាដែលអាចបញ្ជាក់យ៉ាងច្បាស់ថា បើការប្រកាន់ក្នុងគំនិតថា មានហេតុផលដែលគួរឲ្យជឿជាក់បាន ដើម្បីសង្ស័យទៅលើជនដែលត្រូវបានចាប់ខ្លួនថា បានប្រព្រឹត្តបទល្មើសមួយ គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ដើម្បីឲ្យការបន្តការឃុំខ្លួនមានលក្ខណៈត្រឹមត្រូវ ក៏ប៉ុន្តែ នៅវេលាណាមួយនោះ លក្ខខណ្ឌនេះលែងគ្រប់គ្រាន់ហើយ។ ក្នុងករណីនេះ ចៅក្រមត្រូវពិនិត្យមើលថា តើហេតុផលដ៏ទៃទៀតដែលបានលើកឡើងដោយ

---

[9] សាលដីកា កថាខណ្ឌទី១៣៧

[10] ដីកា កថាខណ្ឌទី១៩

អាជ្ញាធរតុលាការ នៅតែបន្តផ្តល់ភាពស្របច្បាប់ដល់ការដកហូតសិទ្ធិសេរីភាពពីជនត្រូវចោទ នោះដែរឬទេ។[11]

### ៣. អំពីការអនុវត្តលក្ខខណ្ឌនៃវិធាន ៦៣.៣.ខ)

➢ **ការដោះលែងលោក ខៀវ សំផន មិនបានបង្កើតជាហានិភ័យដល់កិច្ចដំណើរការជំនុំជម្រះរបស់ អ.វ.ត.ក ឡើយ (វិធាន ៦៣.៣.ខ) (១) (២) និង (៣) )**

១៤. វាមានការចាំបាច់ ក្នុងការរំលឹកអំពីសេចក្តីសន្និដ្ឋាននានារបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលថា *"មិនមានហានិភ័យណាមួយកើតឡើង (...) ដែលថាលោក ខៀវ សំផន អាចធ្វើការគៀបសង្កត់ទៅលើជនរងគ្រោះ និងសាក្សី (...) ក៏ដូចជាមិនអាចប្រើប្រាស់នូវឥទ្ធិពលណាមួយដើម្បីធ្វើការគៀបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ ឬដើម្បីបំផ្លាញនូវភស្តុតាងណាមួយឡើយ"* ហើយ ហានិភ័យចំពោះការរត់គេចខ្លួនក៏មិនអាចកើតមានផងដែរ នៅពេលដែលរូបគាត់ត្រូវបានគេដោះលែងនោះ។[12]

១៥. សហចៅក្រមស៊ើបអង្កេត មិនបានបង្ហាញនូវអង្គហេតុថ្មីណាមួយដែលអាចធ្វើជាមូលដ្ឋានក្នុងការបដិសេធទៅនឹងសេចក្តីសន្និដ្ឋានទាំងនោះឡើយ ហើយក៏មិនបានលើកឡើងនូវអំណះអំណាងថ្មីណាមួយដើម្បីជំទាស់ទៅនឹងអង្គហេតុដែលថា ការឃុំខ្លួនលែងមានលក្ខណៈចាំបាច់ ហើយ បើផ្អែកទៅលើហេតុផលទាំងបីយ៉ាងនោះ។

➢ **ការដោះលែងលោក ខៀវ សំផន មិនបានបង្កើតឱ្យមានជាហានិភ័យណាមួយ ចំពោះរូបគាត់ឡើយ (វិធាន ៦៣.៣.ខ).(៤) )**

---

[11] សូមពិនិត្យមើលជាពិសេស តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សាលដីកា *Belchev ប្តឹងពីប្រទេស ប៊ុលហ្គារី ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៤* ពាក្យបណ្តឹងលេខ ៣៩២៧០/៩៨ (កថាខណ្ឌទី៧៤) ឬ សាលដីការបស់ *Labita ប្តឹងពីប្រទេសអ៊ីតាលី ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០* ពាក្យបណ្តឹងលេខ ២៦៧៧២/៩៥ (កថាខណ្ឌទី១៥៣)

[12] សាលដីកា កថាខណ្ឌទី៤៨

00420930



១៦. នៅក្នុងដីកាសម្រេចចុះថ្ងៃទី១៨ ខែវិច្ឆិកា សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា *"ចាប់តាំងពីពេលចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមក មិនមានការប្រែប្រួលនៃកាលៈទេសៈ ដែលអាចនាំឲ្យមានសេចក្តីសន្និដ្ឋានខុសផ្សេងពីនោះទេ ។"*[13]

១៧. ជាបឋម សហមេធាវីការពារសូមរំលឹកនូវអំណះអំណាងនានាដែលបានលើកឡើងនៅក្នុងសេចក្តីជំទាស់របស់ខ្លួន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ [14] ដែលថា អង្គហេតុនានាដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះគ្មានមូលដ្ឋានដែលអាចឱ្យគេសន្និដ្ឋានបានថា មានហានិភ័យពិតប្រាកដ និងជាក់ស្តែងដល់សុវត្ថិភាពផ្ទាល់របស់លោក ខៀវ សំផន ឡើយ។ លោក ខៀវ សំផន ក៏មិនមានការព្រួយបារម្ភណាមួយចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ដែរ។

១៨. លើសពីនេះ សហមេធាវីការពារក៏បានលើកឡើងផងដែរថា សហចៅក្រមស៊ើបអង្កេត ជាអ្នកដែលត្រូវលើកសម្អាងភស្តុតាងបញ្ជាក់អំពីកាលៈទេសៈនានា ដែលអាចគំរាមកំហែងដល់សន្តិសុខរបស់លោក ខៀវ សំផន ហើយត្រូវបញ្ជាក់អំពីហេតុផលដែលតម្រូវឲ្យមានការឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន នោះ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីព្រឹត្តិការណ៍ដែលកើតមាននៅឆ្នាំ១៩៩១ ២០០០ និង២០០៨ ដែលសុទ្ធសឹងជាព្រឹត្តិការណ៍ដែលកើតមានឡើងមុនពេលចេញដីកាសម្រេចបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នដំបូងបំផុត ប៉ុន្តែមិនបានលើកឡើងពីស្ថានភាពដែលកើតមានក្នុងពេលបច្ចុប្បន្នឡើយ។ ដូចដែលបានបញ្ជាក់ពីខាងដើម ដីកាសម្រេចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែពិនិត្យសារជាថ្មីទៅលើកាលៈទេសៈដែលកើតមានក្នុងពេលបច្ចុប្បន្ននៃការចេញដីកាសម្រេចនោះ ប៉ុន្តែមិនត្រូវយោងតែទៅលើអង្គហេតុដែលកើតមានក្នុងពេលអតីតកាលនោះទេ។

១៩. ផ្ទុយទៅវិញ មិនមានភស្តុតាងណាមួយដែលអាចឲ្យគេសន្និដ្ឋានបានថា សន្តិសុខរបស់លោក ខៀវ សំផន ត្រូវបានគំរាមកំហែង នៅពេលដែលគាត់ត្រូវបានគេដោះលែងឲ្យមានសេរីភាពនោះ។ ជាទីបញ្ចប់ វាជាការចាំបាច់ក្នុងការដែលតម្រូវឲ្យមានការដោះលែងរូបលោក ខៀវ សំផន នៅក្នុង លក្ខខណ្ឌនានាដែលអាចធានាសន្តិសុខដល់រូបគាត់បាន។

---

[13] ដីកាសម្រេច កថាខណ្ឌទី២៤

[14] សេចក្តីជំទាស់ កថាខណ្ឌទី១២ ដល់ ១៥

➢ **ការដោះលែងលោក ខៀវ សំផន មិនបានបង្កើតឱ្យមានជាហានិភ័យដែលគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឡើយ (វិធាន ៦៣.៣.ខ). (៥) )**

២០. ត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា *"ចាប់ពីពេលនៃការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមក វាមិនមានការប្រែប្រួលនៃកាលៈទេសៈ ដែលអាចនាំឱ្យមានសេចក្តីសន្និដ្ឋានខុសផ្សេងពីនោះឡើយ ។"*[15]

២១. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា *"ការជំនុំជម្រះរឿងក្តីខ្មែរក្រហម នៅតែជាបញ្ហាដែលសព្វថ្ងៃប្រជាជនកម្ពុជាមានការយកចិត្តទុកដាក់ជាខ្លាំង"* [16]។

២២. តថភាពនៃការយកចិត្តទុកដាក់នេះមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះទេ ប៉ុន្តែវាច្បាស់ណាស់ថា តថភាពនេះមិនបានផ្សាភ្ជាប់ជាមួយបុគ្គលលោក ខៀវ សំផន ទេ ប៉ុន្តែវាបានផ្សាភ្ជាប់ទៅនឹងដំណើរការនៃការជំនុំជម្រះសេចក្តីទាំងមូល និងផ្សាភ្ជាប់ជាមួយបរិបទនៃសង្គមខ្មែរទាំងមូល។ ក្នុងពេលបង្កើតអ.វ.ត.ក ការឃុំខ្លួនត្រូវបានគេចាត់ទុកថាជាករណីអញ្ញត្រកម្មទៅនឹងគោលការណ៍នៃសេរីភាព។ នៅក្នុងដំណាក់កាលនៃការតាក់តែងលក្ខន្តិកៈ បរិបទនៃសង្គមកម្ពុជា និងស្នាមរបួសដែលប្រជាជនកម្ពុជានទទួលរង គឺជារឿងដែលគេដឹងឮគ្រប់ៗគ្នា ហើយគ្មាននរណាម្នាក់បានគិតឃើញទាល់តែសោះថា ដំណើរប៉ះទង្គិចទៅលើប្រជាជនកម្ពុជាដែលអាចកើតមានឡើងក្នុងពេលចាប់ផ្តើមនីតិវិធី មិនត្រូវបានគេដាក់បញ្ចូលទៅក្នុងការតាក់តែងវិធាននេះទេនោះ។ អ.វ.ត.ក ស្ថិតនៅក្នុងចង្កោមជាមួយតុលាការអន្តរជាតិនានា ជាពិសេសតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី(TPIY)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ត្រូវបានបង្កើតឡើងក្នុងបរិបទដ៏ស្មុគស្មាញមួយនៅក្នុងតំបន់ ពោលគឺនៅក្នុងតុលាការនោះ មិនមានយន្តការណាមួយអាចទប់ស្កាត់ចៅក្រមក្នុងការសម្រេចដោះលែង មុនពេលចាប់ផ្តើមធ្វើការជំនុំជម្រះ នូវជនជាប់ចោទដែលមានចំនួនដ៏ច្រើនមហិមា ហើយអនុញ្ញាតឱ្យពួកគេវិលត្រលប់ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ ដោយគ្មានគិតថា ទង្វើនេះអាចបង្កើតឱ្យមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ដែលគួរតែមិនត្រូវអនុវត្តឡើយ។

---

[15] ដីកា កថាខណ្ឌទី២៧

[16] ដីកា កថាខណ្ឌទី២៦

២៣. ក្នុងករណីនេះ មេធាវីការពារសូមរំលឹកផងដែរថា ភាពទន់ខ្សោយនៃបរិបទរបស់សង្គមកម្ពុជា ត្រូវបានសង្កេតឃើញថាមានលក្ខណៈឆ្ងាយហួសពីការពិត ហើយប្រសិនណាជាគេជឿជាក់ថា ភាពតានតឹងក្នុងអារម្មណ៍នានា ពិតជាអាចបង្កើតនូវការគំរាមកំហែងណាមួយទៅលើជនរងគ្រោះមែន នោះគេពុំអាចអះអាងថាការដោះលែងលោក ខៀវ សំផន នឹងអាចបង្កើតឱ្យមានយ៉ាងជាក់ច្បាស់នូវការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។ វាជាសញ្ញាណពីរដែលមាន លក្ខណៈខុសគ្នា ហើយដែលមិនអាចច្រលំគ្នាបានទេ។ [17]

២៤. ទីបញ្ចប់ វាជារឿងមួយគួរឱ្យភ្ញាក់ផ្អើលដែលអង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានថា ជនត្រូវចោទ មិនបានបង្កើតឱ្យមានហានិភ័យណាមួយចំពោះសាក្សីឬជនរងគ្រោះឡើយ ផ្ទុយទៅវិញបានបង្កើត នូវការគំរាមកំហែងដល់បូរណភាពផ្លូវចិត្តនៃជនដែលពុំជាប់ទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចដំណើរការជំនុំជម្រះសេចក្តីទៅវិញ។

២៥. ជាលទ្ធផល គេពុំអាចចាត់ទុកថាការបន្តឃុំខ្លួនលោក ខៀវ សំផន ជារឿងមួយចាំបាច់សម្រាប់ថែរក្សាសណ្តាប់ធ្នាប់សាធារណៈឡើយ។

### ៤. ដោយពិនិត្យលើកាលៈទេសៈទាំងឡាយ មានតែការដោះលែងទេដែលត្រឹមត្រូវ

---

[17] ករណីនេះ ក្នុងសាលដីការបស់តុលាការ ឌូអាយ ដែលនៅក្នុង នោះបានលើកយកមកវែកញែកពីភាពច្របូកច្របល់គ្នារវាង ទម្ងន់នៃអង្គហេតុ និងការបង្ករការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សាលដីកានេះអាចឱ្យយើងយល់ពីភាពខុសគ្នានៃសញ្ញាណទាំងពីរនេះ។ នៅក្នុងសំណុំរឿងនេះ វាច្បាស់ណាស់ថា ជនរងគ្រោះទទួលរងព្យសនកម្មធ្ងន់ធ្ងរ ក៏ប៉ុន្តែអ្វីដែលត្រូវតែរកភស្តុតាងមកបញ្ជាក់ មិនមែនការបន្តមាននូវការប៉ះពាល់ដល់ជនរងគ្រោះទេ គឺការបន្តមាននូវការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឯណោះទេ។ តុលាការបានធ្វើការសន្និដ្ឋានក្នុងន័យនេះថា "មិនអាចអះអាងបានទេថា អង្គហេតុទាំងនេះបណ្តាលឱ្យមាន "ការប៉ះពាល់ពិសេស និងជាអចិន្ត្រៃយ៍ណាមួយ" ដល់សណ្តាប់ធ្នាប់សាធារណៈទេ។ ការឈឺចាប់បច្ចុប្បន្នកាលរបស់ជនរងគ្រោះមិនអាចឱ្យសន្មតបានថា ការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដែលត្រូវបញ្ជាក់ដោយអង្គហេតុនៅឆ្នាំ១៩៩៧ (ដែលចាត់ទុកថា ជាការប៉ះពាល់"ពិសេស") នៅក្នុងរឿងនេះ រហូតថាទាល់តែមានការឃុំខ្លួនបណ្តោះអាសន្នរបស់ជនX" ទើបអាចបញ្ចប់បញ្ហានេះបានទេ។ អាការៈមិនប្រក្រតីនាពេលបច្ចុប្បន្នរបស់ជនរងគ្រោះគឺមិនដូចទៅនឹងការប៉ះពាល់"ដែលបន្តមាន" ទៅលើសណ្តាប់ធ្នាប់សាធារណៈទេ។ CHAMBON (P.), GUERY (C.), *Droit et pratique de l'instruction préparatoire*, Dalloz Action 2007/2008, កថាខណ្ឌ 142.43.

២៦. ដូចដែលសហមេធាវីការពារបានលើកឡើងនៅក្នុងសេចក្តីជំទាស់របស់ខ្លួន[18] *"ការជាប់ទាក់ទងរវាងរយៈពេលដែលចុងចោទជាប់ឃុំខ្លួន និងការខិតខំប្រឹងប្រែងក្នុងការអនុវត្តកិច្ចស៊ើបអង្កេតគឺជាកត្តាទាក់ទងគ្នាមួយក្នុងការពិចារណាបន្តការឃុំខ្លួន ឬក៏ការដោះលែងឱ្យមានសេរីភាព"*។[19] សហចៅក្រមស៊ើបអង្កេត បានឯកភាពទៅលើការវិភាគនេះ និងបានផ្តល់នូវភស្តុតាងនានាស្តីពីការងារ ដែលខ្លួនបានបំពេញ ដើម្បីបង្ហាញថា ខ្លួនបានអនុវត្តកិច្ចស៊ើបអង្កេតយ៉ាងសកម្មនោះ។

២៧. នៅត្រង់កថាខណ្ឌទី៣១ នៃដីកាសម្រេច សហចៅក្រមស៊ើបអង្កេតបានអះអាងថាខ្លួនបាន *"រៀបចំឱ្យមាន ការស្តាប់ចម្លើយសាក្សី និងបានដាក់បញ្ចូលក្នុងសំណុំរឿងផងដែរ នូវភស្តុតាងទាំងតាមរយៈសំណើសុំរបស់ភាគី និងតាមរយៈការផ្តួចផ្តើមផ្ទាល់ ។ "*[20] ការគណនាដ៏លឿនអំពីឯកសារដែល ផ្តល់ដោយសហចៅក្រមស៊ើបអង្កេត អាចឱ្យយើងសន្និដ្ឋានបានថា សហចៅក្រមស៊ើបអង្កេតបានធ្វើការសម្ភាសទៅលើសាក្សី និង/ឬ ជនរងគ្រោះចំនួនប្រហែល ៣០ នាក់ ចាប់តាំងពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដូច្នេះជារៀងរាល់ខែ មានសាក្សី៣ នាក់ត្រូវបានសម្ភាស។ ផ្អែកទៅលើព័ត៌មាននេះ យើងមានការលំបាកក្នុងការសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេតបាន បំពេញការងារស៊ើបអង្កេតរបស់ខ្លួនយ៉ាងសកម្ម ដែលអាចចាត់ទុកថាមានហេតុផលសមស្របក្នុងការបន្តឱ្យមានការឃុំខ្លួនទៅលើរូបលោក ខៀវ សំផន។

២៨. ស្របទៅនឹងគោលការណ៍សន្មតថាគ្មានទោស សិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយសមធម៌ និងជាពិសេសសិទ្ធិក្នុងការទទួលបានការស្តាប់ហេតុផលពីសំណាក់តុលាការមួយដែលមានលក្ខណៈអនាគតិ និងឯករាជ្យ គឺជាសរសរគ្រឹះនៃគ្រប់ប្រព័ន្ធតុលាការទាំងអស់ដែលមានលក្ខណៈស្តង់ដារអន្តរជាតិ។

---

[18] សេចក្តីជំទាស់ កថាខណ្ឌទី៨

[19] សេចក្តីជំទាស់ កថាខណ្ឌទី៨ ដែលលើកអំពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេច បដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌទី៦៨

[20] សាលដីកា កថាខណ្ឌទី៣១

00420934



២៩. ថ្ងៃទី៣ កក្កដា ២០០៩ អង្គបុរេជំនុំជម្រះពិចារណាឃើញថា រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ គឺសមហេតុផល ដោយពិចារណាទៅលើ បទឧក្រិដ្ឋដែលកំពុងត្រូវបានស៊ើបអង្កេត និងកិច្ចស៊ើបអង្កេតដែលសហចៅក្រមស៊ើបអង្កេតបានបំពេញ។"[21]

៣០. ដូច្នេះ ក្រៅពីជាកម្មវត្ថុនៃការស៊ើបអង្កេត វាជាការតម្លៃថា តើអាជ្ញាធរតុលាការបានបង្ហាញពីការយកចិត្តទុកដាក់គ្រប់គ្រាន់ ដើម្បីឱ្យការបន្តការឃុំខ្លួនគឺជាវិធានការមួយដ៏សមស្រប អាចឆ្លើយតបទៅនឹងគោលបំណងយ៉ាងត្រឹមត្រូវ និងស្របច្បាប់របស់ប្រព័ន្ធតុលាការ និងមិនមែនជាទង្វើដោយបំពាននោះឡើយ។

២៩. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតមិនបានឆ្លើយតបទៅនឹងអំណះអំណាងទាំងឡាយដែលលើកឡើងដោយមេធាវីការពារ អំពីការរំលោភជាប្រព័ន្ធទៅលើគោលការណ៍សន្មតថាគ្មានទោស និងសិទ្ធិទាំងឡាយរបស់លោក ខៀវ សំផន ទេ។ ដូច្នេះសហចៅក្រមស៊ើបអង្កេតមិនបានគោរពទៅតាមសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ ដែលស្នើសុំឱ្យមានការពិនិត្យ ជាពិសេសទៅលើ *"ការអនុវត្តនីតិវិធីទាំងមូល"*[22] ដើម្បីសម្រេចថា តើថេរវេលានៃការឃុំខ្លួនពិតជាសមស្របមែននោះ។ អំណះអំណាងអស់ទាំងនេះ មិនត្រូវបានគេយកមកពិនិត្យពិចារណាឡើយ។

៣០. ជាក់ស្តែង កំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតត្រង់ចំណុចនេះ បានឆ្លើយតបទៅនឹងអារម្មណ៍របស់មេធាវីការពារ ដែលយល់ឃើញថា ខ្លួនកំពុងទទួលរងនូវភាពលំអៀងយ៉ាងជាក់ច្បាស់។ ភាពលំអៀងនេះត្រូវតែបានបដិសេធចោល និងត្រូវទទួលនូវការដាក់ទោស។ ក្នុងករណីស្រដៀងគ្នានេះ តុលាការកំពូលបារាំងបានសម្រេចលុបចោលសាលដីកាសម្រេចសាលាឧទ្ធរណ៍ ដោយតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ចៅក្រមសាលាឧទ្ធរណ៍ដែលមានលក្ខណៈបំភ័ត្ត បានធ្វើឱ្យមេធាវីការពារមានការសង្ស័យទៅលើភាពអនាគតិ (*ភាពមិនលំអៀង*) របស់ចៅក្រមនោះ[23]។ ដូច្នេះ ករណីនេះវាដូចគ្នាទាំងស្រុងទៅនឹងករណីរបស់ អ.វ.ត.ក ដែរ។

---

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី៣ កក្កដា ២០០៩ ឯកសារតុលាការ C26/5/26 កថាខណ្ឌ ៧៥។

[22] សាលដីកា កថាខណ្ឌទី៦៩

[23] តុលាការកំពូល សភាការងារ អង្គជំនុំជម្រះសាធារណៈ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ បណ្តឹងសារទុក្ខលេខៈ ០៧. ៤០៣១២

៣១. ដូចដែលបានលើកឡើងក្នុងសេចក្តីជំទាស់របស់ខ្លួន សហមេធាវីការពារយល់ឃើញថា យោងទៅលើកាលៈទេសៈនៃការអនុវត្តនីតិវិធីទាំងមូល មានតែការដោះលែងមួយគត់ដែលសមស្របចំពោះករណីនេះ។ ជាក់ស្តែង បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលពីរឆ្នាំរួចមក សហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន នៅតែមិនទាន់បានទទួលនូវសំណុំឯកសារភស្តុតាងដែលបានដាក់បញ្ចូលក្នុងសំណុំរឿងស៊ើបអង្កេត ឬសេចក្តីសន្និដ្ឋាន និងសំណើសុំរបស់គូភាគីនៅឡើយទេ ដែលឯកសារភស្តុតាងទាំងនោះត្រូវបានចាត់ទុកថាមានសារសំខាន់សម្រាប់ធានាឱ្យមានការកាត់សេចក្តីដោយសមធម៌[24]។ ការចោទប្រកាន់អំពីអំពើពុករលួយ បានគ្រប់ដណ្តប់លើនីតិវិធី ហើយការស៊ើបអង្កេតទៀតសោត ក៏មិនបានអនុវត្តក្នុងក្របខណ្ឌនៃតម្លាភាពដែរ[25]។ សហមេធាវីការពារបានលើកឡើងជារឿយៗនូវសំណួរនានាដែលពាក់ព័ន្ធនឹងកង្វះខាតនូវភាពហ្មត់ចត់ ក្នុងការស៊ើបអង្កេត[26] ហើយនិងការលេចឡើងនូវភាពសង្ស័យចំពោះភាពមិនលំអៀងនៃស្ថាប័នស៊ើបអង្កេតផងដែរ។[27]

## IV. អាស្រ័យហេតុនេះ

៣៤. សហមេធាវីការពារក្តីលោក ខៀវ សំផន សូមឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាពឡើងវិញ។

**អភ្យាសិទ្ធិកែប្រែគ្រប់បែបយ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | |
|---|---|---|
| មេធាវី **ស សុវាន**<br>មេធាវី **Jacques VERGÈS** | ភ្នំពេញ<br>ប៉ារីស | P. |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[25] សេចក្តីជំទាស់ កថាខណ្ឌទី២៦

[26] សេចក្តីជំទាស់ កថាខណ្ឌទី២៧

[27] សេចក្តីជំទាស់ កថាខណ្ឌទី២៨